# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជានៅព្រះសហគមន៍ព្រះត្រៃឯក
# គិរីរម្យ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២០
## សុភមង្គលពិតប្រាកដគឺយើងបានធ្វើឲ្យអ្នកដទៃមានសេចក្តីសុខ

**អត្ថបទទី១៖ បេនស៊ីរ៉ាក់ ១៥,១៥-២០**

ប្រសិនបើកូនមានបំណងប្រតិបត្តិតាមវិន័យរបស់ព្រះអម្ចាស់ នោះកូនមុខជាប្រតិបត្តិតាមបាន។ កូនអាចស្មោះត្រង់នឹងព្រះអង្គបាន តាមការសម្រេចចិត្តរបស់កូន។ បសរ ១៥,១៥

**អត្ថបទទី២៖ កូរិនថូសទី១ ២,៦-១០**

គ្មាននរណាម្នាក់ក្នុងចំណោមអ្នកគ្រប់គ្រងមនុស្សលោកនេះ បានស្គាល់ប្រាជ្ញារបស់ព្រះអង្គទេ ប្រសិនបើគេពិតជាបានស្គាល់មែន គេមិនឆ្កាងព្រះអម្ចាស់ប្រកបដោយសិរីរុងរឿងនោះឡើយ។ ១ករ ២,៨

**ដំណឹងល្អ៖ ម៉ាថាយ ៥,១៧-៣៧**

អ្នកណាប្រតិបត្តិតាមវិន័យ ហើយបង្រៀនអ្នកផ្សេងឲ្យប្រតិបត្តិតាម អ្នកនោះនឹងមានឋានៈធំក្នុងព្រះរាជ្យនៃស្ថានបរមសុខ។ មថ ៥,១៩ខ

បងប្អូនជាទីស្រឡាញ់!

ឆ្នាំនេះ យើងគោរព៣០ឆ្នាំដែលព្រះសហគមន៍ភូមិភាគភ្នំពេញមានជីវិតរស់ឡើងវិញ នៅសម័យប៉ុលពតបានបំផ្លាញសាសនាទាំងអស់ក្នុងប្រទេសកម្ពុជា។ នៅឆ្នាំ១៩៩០ យើងបានថ្វាយអភិបូជាសាជាថ្មីជាលើកដំបូងនៅបុណ្យចម្លង ជាឱកាសមួយសម្រាប់ព្រះសហគមន៍នីមួយៗសរសេរអំពីប្រវត្តិសាស្ត្រព្រះសហគមន៍ផ្ទាល់ខ្លួន។ អត្ថបទទី១ដែលយើងបានស្តាប់ថ្ងៃនេះ ជាអត្ថបទមួយដែលយើងត្រូវការទុកនៅក្នុងចិត្តរបស់យើង "**ព្រះអង្គដាក់ទឹកនឹងភ្លើងនៅមុខកូន កូនអាចលូកដៃជ្រើសរើសយកមួយណាក៏បានតាមចិត្តកូនប្រាថ្នា ព្រះអង្គប្រទានឲ្យមនុស្សលោកមានជីវិតឬស្លាប់តាមតែម្នាក់ៗជ្រើសរើស**"។ នៅមុខយើងមានភ្លើងដែលឆេះ និងយើងមានទឹកត្រជាក់ **តើយើងដាក់ដៃនៅក្នុងភ្លើងឬនៅក្នុងទឹក?** យើងត្រូវការជ្រើសរើសផ្លូវមួយ។ ជីវិត ជាទ្រព្យសម្បត្តិដែលយើងបានទទួល យើងជ្រើសរើសអំពើល្អដែលណែនាំឲ្យជីវិតរបស់យើងប្រសើរឡើងៗ ឬយើងជ្រើសរើសអំពើអាក្រក់ដែលណែនាំឲ្យជីវិតរបស់យើងធ្លាក់ចុះ។

ពីមួយថ្ងៃទៅមួយថ្ងៃយើងត្រូវការជ្រើសរើស នៅថ្ងៃអាទិត្យយើងត្រូវជ្រើសរើសយើងមកព្រះវិហារឬយើងទៅដើរលេង។ យើងត្រូវការមើល មានអ្វីខ្លះដែលណែនាំឲ្យចិត្តគំនិតរបស់ខ្ញុំរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ រីកចម្រើននៅក្នុងសេចក្តីសុខសាន្តនិងសុភមង្គល។ កុំឲ្យជីវិតរបស់យើងទៅជាជីវិតអាត្មានិយម គិតអំពីសេចក្តីសុខផ្ទាល់ខ្លួន គិតអំពីសុភមង្គលផ្ទាល់ខ្លួន។ ឲ្យយើង

យល់ថា សេចក្ដីសុខសាន្ត និងសុភមង្គលដ៏ពិតប្រាកដ នៅមានពេលខ្ញុំណែនាំឲ្យអ្នកដទៃខ្ញុំមានសេចក្ដីសុខនិងសុភមង្គល។ យើងធ្លាប់ស្ដាប់អត្ថបទមួយថា ព្រះយេស៊ូបានអប់រំមហាជនបីយប់បីថ្ងៃ ហើយព្រះអង្គឃើញពួកគេឃ្លានព្រះយេស៊ូមានព្រះបន្ទូលទៅក្រុមគ្រីស្ដទូតថា ដល់ពេលវេលាឲ្យម្ហូបអាហារឲ្យគេបរិភោគ។ នៅក្នុងចំណោមពួកគេមានតែនំប៉័ងនិងត្រីតិចតួច ព្រះយេស៊ូអធិដ្ឋានហើយចែកនំប៉័ងនិងត្រីទៅមហាជនបានញាំឆ្អែតគ្រប់ៗគ្នា។ យើងឃើញព្រះយេស៊ូមិនឲ្យទទេ ព្រះអង្គប្រមូលអ្វីដែលគេមានហើយ សម្រាប់អ្នកដែលបានឲ្យនំប៉័ងនិងត្រីគេចិត្តល្អណាស់គេឃ្លានមែនប៉ុន្តែគេបានចែករំលែកអ្វីដែលគេមាន។ យើងមានសុភមង្គល លុះត្រាតែយើងសុខចិត្តចែករំលែកអ្វីដែលយើងមានដល់បងប្អូនឯទៀតៗ សុភមង្គលមិនមែនសម្រាប់យើងផ្ទាល់គឺយើងធ្វើឲ្យបងប្អូនឯទៀតៗគេមានសេចក្ដីសុខ។

នៅពេលយើងចែករំលែកអ្វីដែលយើងមាន ដើម្បីណែនាំឲ្យអ្នកដទៃមានសេចក្ដីសុខយើងដឹងថា យើងរកឃើញសុភមង្គលដ៏ពិតប្រាកដ។ យើងនឹងទទួលបានរង្វាន់ធំពីព្រះជាម្ចាស់ដោយសារបងប្អូនឯទៀតៗអាចមានអំណរសប្បាយ ឲ្យយើងជ្រើសរើសអ្វីដែលត្រឹមត្រូវដោយចេះចែករំលែកឲ្យគ្នាទៅវិញទៅមក។ ព្រះយេស៊ូបានណែនាំឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមកឲ្យយើងយកចិត្តទុកដាក់អស់ពីសមត្ថភាពលើអ្វីដែលយើងធ្វើ។ នៅពេលយើងជ្រើសរើសអំពើល្អដើម្បីណែនាំឲ្យអ្នកដទៃមានសុភមង្គល នោះយើងរកឃើញសេចក្ដីសុខនៅក្នុងខ្លួន និងណែនាំឲ្យយើងរីកចម្រើននៅក្នុងជីវិតយើងខ្លាំងទៅៗ។ យើងអធិដ្ឋាន ដើម្បីឲ្យយើងរួមគ្នាឲ្យយើងទៅជាមនុស្សសកម្ម ទោះបីយើងមានតិចក៏ដោយឲ្យយើងចេះចែករំលែកដល់បងប្អូនឯទៀតៗ នោះព្រះជាម្ចាស់នឹងប្រទានឲ្យយើងលើសពីអ្វីដែលយើងបានចែករំលែកទៅទៀត។ ព្រះជាម្ចាស់ដឹងពីអ្វីៗទាំងអស់ដែលយើងត្រូវការ និងស្គាល់ដួងចិត្តរបស់យើង ហេតុនេះហើយព្រះអង្គមិនបញ្ជាឲ្យនរណាម្នាក់ប្រព្រឹត្តបទល្មើសទេ ព្រះអង្គក៏មិនអនុញ្ញាតឲ្យនរណាម្នាក់ប្រព្រឹត្តអំពើបាបដែរ។ ឲ្យយើងខិតខំធ្វើជាមនុស្សល្អ ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាពន្លឺមួយសម្រាប់បងប្អូនឯទៀតៗជានិច្ច។ អាម៉ែន៕